**សុន្ទរកថារបស់ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ**
**ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ**
**សម្រាប់គម្រោងទ្រទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ**
**ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៤**

- សូមគោរព **លោកវេជ្ជបណ្ឌិត ស្រី ស៊ីន** ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ធំ
- សូមគោរព ភ្ញៀវកិត្តិយស លោកស្រី និងអស់លោកទាំងអស់

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការរៀបចំពិធីចុះហត្ថលេខាផ្តល់ជំនួយឧបត្ថម្ភឥតសំណងរបស់ប្រទេសជប៉ុនដល់មន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ។

គម្រោងដែលមានថវិកាសរុប **ចំនួន ៨២,៦១៥ ដុល្លាអាមេរិក** គឺសម្រាប់ការជួសជុលអគារជម្ងឺឆ្លងក្នុងមន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ ក្នុងគោលបំណង ដើម្បីអោយអ្នកជម្ងឺទទួលបានការព្យាបាលកាន់តែមានភាពប្រសើរជាងមុន នៅក្នុងបរិស្ថានដែលកាន់តែមានសុវត្ថិភាព និងការយកចិត្តទុកដាក់បន្ថែមទៀត។ គម្រោងនេះរំពឹងថានឹងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋប្រមាណ ៦៦០,000 នៅក្នុងតំបន់។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំប្រឹងប្រែងធ្វើយ៉ាងណា ដើម្បីជួយសម្រួលដល់ស្ថានភាពសុខភាពអោយកាន់តែមានភាពប្រសើរឡើង។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានផ្តល់អាទិភាពទៅលើការកែលម្អស្ថានភាពសុខភាពអោយកាន់តែប្រសើរឡើង។ ខណៈដែល ខ្ញុំអបអរដល់ប្រទេសកម្ពុជាសម្រាប់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៅក្នុងវិស័យសុខាភិបាល ប្រទេសកម្ពុជានៅតែចាំបាច់ត្រូវធ្វើការបន្ថែមទៀតដើម្បីកែលម្អស្ថានភាពសុខភាពអោយកាន់តែប្រសើរឡើង។

ខ្ញុំសង្ឃឹមថាគម្រោងដែលយើងបានចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយនៅថ្ងៃនេះ នឹង ត្រូវបានអនុវត្តដោយរលូន និងប្រ កបដោយប្រសិទ្ធភាពដោយដៃគូរបស់យើងគឺមន្ទីរសុខាភិបាលខេត្តកំពង់ធំ ហើយនឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវ ដើម្បីប្រជាជនកាន់តែច្រើន អាចទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានស្រាប់រវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណ!